ឧបសៅ សង្ហា

# ការបបួលគ្នាប្រកួត នៃ គណបក្សសង្គ្រោះជាត



## មាតិការឿង


បុព្វកថា ........................................................................ 2

ការពិនិត្យកត់ត្រា នៃ បច្ចុប្បន្នភាពស្រុកខ្មែរ .......... 3

គណបក្សសង្គ្រោះជាត ជា អ្វី ? ...................................... 6

មនោសាស្ត្រ នៃ គណបក្សសង្គ្រោះជាត ................ 13

សេចក្តីសន្និដ្ឋាន ............................................................. 18

# ការបបួលគ្នាប្រកួត នៃ គណបក្ស សង្គ្រោះជាតិ[1]

## បុព្វកថា

លទ្ធផល នៃ ការបោះឆ្នោត ថ្នាក់ជាតិ ក្នុង ឆ្នាំ ២០១៣ ពិត ជា ការលើកទឹកចិត្ត ដល់ គណបក្ស សង្គ្រោះជាតិ ព្រោះ គណបក្ស នេះ ទទួលបាន ជ័យជំនះ ពិត តាម សម្លេង ឆ្នោត បើ គ្មាន ការក្លែង នៃ លទ្ធផល ពី សំណាក់ គ.ជ.ប.[2]។ ជ័យជំនះ នេះ នាំ អោយ គណបក្ស កាន់អំណាច មាន ការភ្ញាក់ផ្អើល ជាខ្លាំង ហើយ ធ្វើអោយ បាត់ស្ថេរភាព បើគ្មាន កម្លាំងយួន ប្រកប់ នៅក្នុង គ្រប់ អំណាចរដ្ឋ ការពារខ្លួន គឺ ច្បាស់ជារលំ ដូច ភ្នំខ្សាច់ ត្រូវ រលកទឹក បោកមកលើ នោះឯង។ តែ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ក៏ មិន បានគិត ថា ពួកខ្លួន អាច ទទួលបានជ័យជំនះ បែបនេះ ដែរ ព្រោះ មិន នឹកស្មាន ថា គណបក្ស កាន់អំណាច ប្រហែសខ្លួន យក ការបោះឆ្នោត២០១៣ ជា ការ ពិសោធន៍ សំរាប់ ស្ទង់ មើល ប្រជាប្រិយភាព ពិត នៃគណបក្សនយោបាយ នៅក្នុង ប្រទេស ដោយ មាន ជំនឿមាំ ថា មិនអាច ចាញ់ ឆ្នោតគណបក្សប្រឆាំង ជា ដាច់ខាត។ មែនទែន តាំងពីដើម ដំបូង មកម្លេះ, ក្រោយពី ការប្រកាសនៃ លទ្ធផល របស់ រដ្ឋមន្ត្រី ក្រសួង ព័តមាន, អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ភាគច្រើន សុខចិត្ត យល់ព្រម ការចែក អាសនៈ នៅក្នុង រដ្ឋសភា ចំនួន ៥៥ ដល់ គណបក្សខ្លួន ព្រោះយល់ឃើញ ថា ចំនួន នេះ អាច ទទួល យកបាន ព្រោះ ជា កម្លាំងស្នូល អាច យក វា មកធ្វើ ជា មូលដ្ឋាន ហិរញ្ញវត្ថុ សំរាប់ គណបក្ស និង ជា កន្លែង សំរាប់បញ្ចេញ វិស័យមតិ នយោបាយ ជា ផ្លូវការ នៅ ក្នុង និង ក្រៅ ប្រទេស ក្នុង ឋានៈ ជា គណបក្សប្រឆាំង។ ជម្រើស នេះ វា ស្របនឹង បុរាណភាសិត ថា «ធ្វើស្រែ នឹងទឹក,ធ្វើសឹក នឹងបាយ» ហើយ វា ក៏ ជា ការភ្នាល់ មួយដែរ របស់ គណបក្ស ថ្វីបើ ជា ជម្រើសខុសពី ឆន្ទៈ ម្ចាស់ឆ្នោត និង ផ្ទុយនឹង គោលការណ៍ នៃ យុត្តិធម៌។ ជម្រើស បែបនេះ វា ប្រកប ទៅ ដោយ គ្រោះថ្នាក់ ព្រោះ គណបក្សសង្គ្រោះជាតិ ប្រឈរមុខនឹង ទ្វេបទ (dilemme) រវាង សីលធម៌ និង កុទិដ្ឋិ (idée contraire à la morale)។ ការជ្រើសរើសយក ផ្លូវ អគតិ នេះ នឹង អាច នាំ ឲ គណបក្ស បាត់បង់ សេចក្ដីទុកចិត្ត ពី អ្នកគាំទ្រខ្លួន។ នៅក្នុង គោលដៅ ចង់ បង្ហាញ ថា ជម្រើស របស់ខ្លួន ជា វិជ្ជមាន អ្នកដឹកនាំ គណបក្ស ជ្រើស យក វិធីសាស្ត្រ សហប្រតិបត្តិការ ឬ វប្បធម៌ សន្ទនា ជាមួយនឹង គណបក្សកាន់អំណាច ដោយ មាន សង្ឃឹម ថា អាចនឹង ធ្វើអ្វី បានខ្លះ សំរាប់ប្រយោជន៍ជាតិ។ ក៏ប៉ុន្តែ ភាពឆ្គង ឬ អស

[1] Le défi du Parti du Salut National.
[2] គណកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ម្ចភាព របស់ លោក សម រង្ស៊ី ក្នុង ការគ្រប់គ្រង វប្បធម៌សន្ទនា នេះ ធ្វើអោយ វា ក្លាយ ជា វិធីសាស្ត្រ មួយ គួរអោយអស់សំណើច ហើយ បាត់អស់នូវ ទុព្វចភាព (rigidité) នៃ គោលការណ៍ ថ្លៃថ្នូរ របស់ គណបក្ស។ យើងយល់ថា គ្រប់ វិនាដកម្ម កើតឡើង ក្រោយ ពី ការបោះឆ្នោត ២០១៣ រហូច មកដល់សព្វថ្ងៃនេះ ជា កម្មវិបាកនៃជម្រើស ផ្លូវអគតិ និង កង្វះ ភាពមផ្ស៊ត របស់ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ នៅក្នុង យុទ្ធសាស្ត្រ នយោបាយ នៃ ការប្រកួត (stratégie politique de compétition) ដែល ខ្លួន គ្រាន់តែ ជា ឧបករណ៍ របស់ គណបក្សកាន់អំណាច តែប៉ុណ្ណោះ។ សួរថា តើ គណបក្សសង្គ្រោះ ជាតិ នៅ មាន សក្តានុពល ដើរ តួ ជា អ្នកអាច ប្តូរ នូវ ជីវិតភាពនយោបាយ ខ្មែរ (la vie politique) បានដែរឬទេ ដែល វា កំពុង ដើរ ស្ទុះលឿនទៅរក អំណាចផ្តាច់ការ ?

យើង សាកល្បង ពិចារណា លើ សំនួរ នេះ នៅ ក្នុង មនោសាស្ត្រ នៃ ឧបេក្ខា (esprit d'impartialité) ហើយ ទុក ការយល់ឃើញ របស់ យើង ជា អត្តនោម័តិ (opinion personnelle) ដូច្នេះ គំនិត ខាងក្រោមនេះ ជា ចំណង់ចិត្ត អោយមាន ការពិភាក្សាសា ជា សាធារណៈ ព្រោះ ការរក ដំណោះស្រាយ នៃ បញ្ហាខ្មែរបច្ចុប្បន្ន វា ត្រូវការ កម្លាំង ជាតិ ហើយ កម្លាំង នេះ វា អាច កើត មាន បាន ពី សំយោគ នៃ គំនិត នៃ អ្នកស្នេហា ជាតិ គ្រប់ មជ្ឈដ្ឋាន គ្រប់ និន្នាការ នយោបាយ។ បើ អ្នកស្នេហាជាតិ រក សំយោគ នេះ ពុំឃើញ គឺ អ្វី ដែល ខ្លួន កំពុង គិត និង កំពុង ធ្វើ វា គ្រាន់តែ ជា គោលវិធី សំរាប់តែ ថែរ អ្នកជម្ងឺ បណ្តោះអាសន្ន ចាំ ដល់ ថ្ងៃ ស្លាប់ តែប៉ុណ្ណោះ (soins palliatifs)។

## ការពិនិត្យកត់ត្រា នៃ បច្ចុប្បន្នភាពស្រុកខ្មែរ

ការពិតមួយ ដែល វា ធ្វើ អោយ បេះដូងខ្មែរ មាន របួស ហើយ ដែល គ្រប់ គណបក្ស នយោបាយ គេ ឈប់ លើកយកវា មក និយាយ ឬ ទុក ជា កត្តា សំខាន់ មាន នៅ ក្នុង បញ្ហាខ្មែរ គឺ កត្តា ជនអន្តោប្រវេសន៍ យួន និង ឥទ្ធិពល ជា ទិស្សមាន (visible) របស់ យៀកណាម មកលើ រដ្ឋាភិបាលខ្មែរ សព្វថ្ងៃ។ កត្តា ទាំងនេះឯង ដែល វា នាំ៚ គ្រប់ ដំណោះស្រាយ រវាង ខ្មែរនឹងខ្មែរ គាំងស្ទះ ព្រោះវា មិនស្រប ទៅនឹង អត្ថ ប្រយោជន៍ យៀកណាម ដែល គេ ទុក ស្រុកខ្មែរ ជា ជីវទឹកដី (espace vitale) សំរាប់ ប្រជាជាតិ និង កត្តា នៃ ស្ថេរភាព របស់ បក្សកុម្មុយនិស្ត យៀកណាម នៅក្នុង ដំបន់ អាស៊ីភាគអគ្នេយ៍។ ទោះបី មាន កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ ជា គ្រិះគតិយុត្ត សំរាប់ ការពារ អធិបតេយ្យភាព និង បូរណភាពទឹកដី ខ្មែរ ក៏ យៀកណា

ម គេ គ្មាន បារម្ភ អំពី ការរំខាន ដល់ គោលដៅ នៃ យុទ្ធសាស្ត្រ នយោបាយ បង្កើត សហព័ន្ធឥណ្ឌូចិន ដែល មាន យៀកណាម ជា អ្នកដឹកនាំ។ ផ្ទុយទៅវិញ កិច្ចព្រមព្រៀង សន្តិភាព នេះ វា ជា មហាជោគជ័យ របស់ យៀកណាម ព្រោះ គេអាច រក្សាបាន តាម ផ្លូវ ច្បាប់ បក្សប្រជាជន ដែល ជា បក្ស រណប គេ អោយ មាន ឥទ្ធពល ខ្លាំងក្លានៅ ក្នុង ជីវិតភាពនយោបាយខ្មែរ។ រហូត មកដល់សព្វថ្ងៃនេះ បក្សប្រជាជន ជា អង្គភាព នយោបាយ ខ្មែរ មួយ ដែល មិនអាច ជៀសវៀងបាន នៅក្នុង ដំណោះស្រាយខ្មែរ មិន តែប៉ុណ្ណោះ ជា គណបក្ស កាន់អំណាច តាំងពី ឆ្នាំ ១៩៧៩ មកម្លេះ មាន គ្រប់ មធ្យោបាយ សំរាប់ រក្សា អំណាចខ្លួន នៅក្នុង យុទ្ធសាស្ត្រ យៀកណាម ដែល ជា អ្នក ការពារខ្លួន តាមផ្លូវ កម្លាំង រូបី ក្តី អរូបី ក្តី។ យៀកណាម ជា ជីវកម្លាំង (force vitale) សំរាប់ គណបក្សប្រជាជនខ្មែរ រឺឯ បក្សប្រជាជនខ្មែរ វិញ ជា ឧបករណ៍ ចាំបាច់ សំរាប់ យុទ្ធសាស្ត្រ យៀកណាម នៅ ដំបន់ ឥណ្ឌូចិន និង នយោបាយ ផ្ទៃក្នុង របស់ បក្សកុម្មុយ និស្តយួន។ អត្ថប្រយោជន៍ រួមនេះឯង ជា បញ្ហា របស់ ប្រជាពលរដ្ឋខ្មែរ ព្រោះខ្លួន គ្មាន ចន្លោះ ណាមួយ អាច ជា ច្រក ចេញ ឲ ផុតពី យុទ្ធសាស្ត្រ យៀកណាម ដើម្បី អាច មាន ដំណោះស្រាយ ខ្មែរ ដោយខ្មែរ និង ដើម្បីខ្មែរ។

អន្តោប្រវេសន៍ ខុសច្បាប់ នៃ ជនជាតិយួន ចូលមកក្នុង ស្រុកខ្មែរ គឺ ជា នយោបាយ របស់ រដ្ឋាភិបាល យៀកណាម មាន ឈ្មោះ ថា នយោបាយ អាណានិគម នៃ ប្រជាជន (politique de la colonisation de peuplement) សំរាប់ ពង្រីក ទឹកដី ប្រជាជាតិ យៀកណាម ដើម្បី ប្រជាជនយួន។ នយោបាយ នេះ នាំអោយ មាន កម្មវិបាក ដល់ ប្រជាជនខ្មែរ ព្រោះ អាណិកជន យួន ចូល មក ក្នុងស្រុកខ្មែរ មាន មនោសាស្ត្រ ជា អ្នក ក្រអឺតក្រអោង, ជា អ្នកផ្សងព្រេង ដណ្តើម យក ទឹកដី ស្រុកខ្មែរ ធ្វើជា កម្មសិទ្ធិ តែ ម្តង ព្រោះ មនោសាស្ត្រ នេះ វាជា សារជាតិ របស់ ជនជាតិយួន ដែល ជា អ្នកច្បាំង ដណ្តើមទឹកដី សំរាប់ ចិញ្ចឹម ជីវិត។ ការប៉ះទង្គិច រវាង ប្រជាពលរដ្ឋ ទាំងពីរ តាំងពី សតវត្ស ទី១៦ មក បង្កើត ជា សង្គ្រាម យោធា រវាង រដ្ឋនឹងរដ្ឋផង និង សង្គ្រាម វប្បធម៌ផង ដែល សុទ្ធ ជា វប្បធម៌ មានចំណាស់ (culture séculaire) ដូចគ្នា មួយទទួល ឥទ្ធិពល ពី ឥណ្ឌា មួយ ទៀត ទទួល ពី ចិន។ ការប៉ះទង្គិចគ្នានេះ គឺ ប្រជាជនយួន ជា អ្នកឈ្នះ តែ ជ័យជំនះ នេះ ពុំមែន មានន័យ ថា ប្រជាជនយួន មាន វិសិដ្ឋភាព នៃ ប្រាជ្ញាខ្ពស់ជាង ប្រជាជនខ្មែរ នោះឡើយ ក៏ប៉ុន្តែ អ្នកដឹកនាំយួន គេ មានល្បិច ច្រើនជាង អ្នកដឹកនាំខ្មែរ ដូច មាន ចែង នៅ ក្នុង បុរាណភាសិតខ្មែរ ថា «សៀម គេ មាន ក្បួន យួន គេ មាន ពុត ឯចំណែក ខ្មែរ វិញ មិន ចោលចែចូវ[3]»។ គេ អាច បកស្រាយ ន័យ នៃ សុភាពសិត នេះ ទុកជា មេរៀនសតិ ថា៖ មនោសាស្ត្រ នៃ ការណ៍និយម (esprit

[3] ចែចូវ ក្នុងន័យ ប៉ុនខាង ពោល ពាក្យញ៉ះញង់, និយាយ ដើមគេ (វចនានុក្រម សម្តេច ជួន ណាត)។

du pragmatisme[4]) របស់ អ្នកដឹកនាំយួន នេះឯង ដែលទុក ជា កត្តា នាំអោយ ប្រជាជាតិយួន មាន ប្រៀប លើខ្មែរ។

នៅក្នុង យុទ្ធសាស្ត្រ នយោបាយ អាណានិគម នៃ ប្រជាជន, អ្នកដឹកនាំយួន នៅស្រុកខ្មែរ គេ មិនគ្រាន់តែ បញ្ចូល ជនជាតិគេ ច្រើន ខ្ទាន់ខ្ទាប់ មកក្នុង ស្រុកខ្មែរ តែប៉ុណ្ណោះទេ គឺ គេមាន នយោបាយ អប់រំ យុវជន ឈានមុខគេ ឲក្លាយ ជា ជន មានគុណភាព រួច គេ បញ្ចូល ឲកាន់ការងារ ជា អ្នកទទួលខុសត្រូវ នៅក្នុង គ្រប់ក្រសួង និង គ្រប់ សារពើច័ក្រ (rouage) នៃ សេដ្ឋកិច្ច ជាតិខ្មែរ។ សព្វថ្ងៃ មុខងារ ធំៗ ជាពិសេស នៅក្នុង រដ្ឋបាល, តុលាការ, នគរបាល, យោធា, សិក្សាធិការជាតិ, ហិរញ្ញវត្ថុសុទ្ធ តែ យួន មាន សញ្ជាតិ ជា ខ្មែរ ជា អ្នកកាន់កាប់ ទាំងអស់។ ការណ៍ នេះ គេ អនុវត្ត ឡើង ក្នុង គោលដៅ រក្សាទុកអោយ ប្រជាជនខ្មែរ ឋិត នៅ ក្នុង ហីនភាព ចំពោះមុខ ប្រជាជនយួន។ ត្រូវដឹងថា ទង្វើ នេះ មាន អនុភាព ព្យតោបាត (effet destructif) ទៅលើ ទឹកចិត្ត យុវជនខ្មែរ នៅ ក្នុង អារម្មណ៍ នៃ អនានុភាព (sentiment d’impuissance) ក្នុង ឋានះខ្លួន ជា ខ្មែរ ម្ចាស់ស្រុក។

អនុត្តរភាព (hégémonie) យៀកណាម មកលើ ស្រុកខ្មែរ តាំងពី ឆ្នាំ ១៩៧៩ មក នាំរំគាយ សង្គមជាតិខ្មែរ ដែល ធ្លាប់មាន សារជាតិ ជា សភាគសង្គម ក្នុងនោះ មាន មូលដ្ឋាន សម្ភារៈ និង សតិ នៃ ជីវិតសង្គម ច្បាស់លាស់ (Base matérielle et spirituelle de la vie sociale précise) ដែល ជា គ្រិះ នៃ ប្រជាជាតិ។ វិបរិត (bouleversement) នេះបំប្លែកជម្មជាតិ នៃសង្គមជាតិខ្មែរ អោយក្លាយជាសង្គមបាត់ វិស្សសភាព (confiance) លើ ខ្លួនឯង, បាត់ សញ្ញាសំគាល់ នៃ អត្តសញ្ញាណជាតិ ដែល ជា ដំណើរ ទៅរក ការវិនាស នៃ ប្រជាជាតិពាន់ឆ្នាំ។ ដើម្បី ធ្វើ អោយ ដំណើរនេះ អោយកាន់តែមាន ជវភាព (ល្បឿន) កាន់តែ លឿនឡើង, អាជ្ញាធរ យៀកណាម នៅ ជំនាន់ អាណានិគមយួន គេបង្កើត សញ្ជាតិថ្មី មាន ឈ្មោះថា សញ្ជាតិកម្ពុជា ក្នុងចំណោមនោះ មាន ជាតិសាសន៍ខ្មែរ, យួន, ចិន, ចាម, ភ្នង, កួយ ។ល។ សញ្ជាតិថ្មី នេះ គឺ សំរាប់ លុបបំបាត់ នៅក្នុងស្មារតី ជាតិសាសន៍ខ្មែរ អោយ រលត់ សាបសូន្យ គំនិត ទុក ខ្លួន ជា ម្ចាស់ស្រុក ព្រោះខ្លួន គ្រាន់តែ ជា សមាសភាព (composant) មួយ នៅក្នុង ចំណោម សមាសភាព ដ៏ទៀត តែប៉ុណ្ណោះ ដូច ជាតិសាសន៍ខ្មែរ នៅ កម្ពុជាក្រោម នោះដែរ។ មកដល់ សព្វថ្ងៃនេះ សញ្ជាតិថ្មី នេះ កំពុង មាន អនុភាព ជា វិជ្ជមាន សំរាប់ យៀកណាម ព្រោះបច្ចុប្បន្នកាល ជនខ្មែរ ភាគច្រើន ហាក់បី ដូចជា ទទួល យក ទស្សនះថ្មី នេះ ជា លទ្ធការណ៍ (fait acquis) នៅក្នុង អារម្មណ៍ នៃ បាតប័ត្រ (résignation) ដើម្បី រស់នៅក្នុង សេចក្តីសុខ មួយខណ: តែប៉ុណ្ណោះ ថ្វីបើ ដឹង ជាក់ច្បាស់ ថា ជីវិតបែបនេះ

[4] Pragmatisme= អ្វីដែលធ្វើឲសម្រេចបានដោយការងារទោះបីលទ្ធផលនោះគ្មានការពិតដាច់ខាតនោះឡើយ។

ជា អន្ទាក់ មរណៈ ដល់ ប្រជាជាតិខ្មែរ ក៏ដោយ។ ការណ៍ នេះ អាច ចាត់ទុក ជា មហាជោគជ័យ របស់ យៀកណាម ដែល អ្នកដឹកនាំ របស់ គេ ខំ ខ្មីឃ្មាត នៅចំពោះមុខ ការខ្ជីខ្ជា របស់ អ្នកដឹកនាំខ្មែរ ដូចយ៉ាង នៅ បុរាណកាល ស្តេចខ្មែរ នាំគ្នា កសាង មហាប្រាសាទ ថ្វាយ អាទិទេព រីឯ ស្តេចយួន វិញ ពាក់ដួន ដើរ រកដីថ្មី ធ្វើ កសិកម្ម សំរាប់ ចិញ្ចឹម កម្លាំង ប្រជាជន ដែល គេទុក ជា ជីវិតិន្ទ្រិយ (force vitale) សំរាប់ ប្រជាជាតិយួន។ សៀវភៅ សរសេរ ដោយ លោក នួន ឃឿន នៅក្នុងឆ្នាំ ១៩៧១ មាន ចំណងជើង ថា «ដំណើរទៅទិសខាងលិច ឬ គល្លូចិន ឆ្នាំ ២០០០» តើ យើង អាច ទុក ចក្ខុវិស័យ របស់ អ្នកនិពន្ធ ជា ការពិត របស់ ខ្មែរ ដែរឬទេ ?

ចម្លើយ វា មាន នៅក្នុង ចក្ខុវិស័យ របស់ គណបក្សសង្គ្រោះជាតិ ព្រោះ គណបក្ស នេះ អះអាង ជា ឧឡារិក ថា ខ្លួន អាច ផ្លាស់ប្តូរ អ្នកដឹកនាំ ដើម្បី ដឹកនាំជាតិ ស្វែងរក ប្រយោជន៍ អោយ ប្រជាជនខ្មែរ។ ការប្រកាស ប្រកប ដោយ កតិកា នេះ ជា ការបបួលប្រកួតគ្នា ជា ថ្មីម្តងទៀត ជាមួយ គណបក្សកាន់អំណាច តាមការបោះឆ្នោត យកឈ្នះដើម្បី ប្តូរ អ្នកដឹកនាំ បច្ចុប្បន្ន។ សួរថា តើ គណបក្សសង្គ្រោះជាតិ អាចមាន លទ្ធភាពនឹង ឈ្នះឆ្នោតបានដែរឬទេ ? ពិតប្រាកដណាស់ថា គណបក្សសង្គ្រោះជាតិ ប្រើ អំណាចនៃ ឆន្ទៈ (pouvoir de la volonté) សំរាប់ ប្រយុទ្ធអហិង្សា ដើម្បី ផ្លាស់ប្តូរ អ្នកដឹកនាំ ហើយ អធិដ្ឋាន នេះ ជុំរុញ ឲ រៀបចំខ្លួន ជាលើកទី២ ដើម្បី ឡើង លើសង្វៀន បោះឆ្នោត ; សួរថា តើ គណបក្ស នឹងប្រើ ក្បាច់គុនថ្មី ឬ យក របៀបចាស់ សំរាប់ ប្រយុទ្ធ ?

## គណបក្សសង្គ្រោះជាតិ ជា អ្វី ?

លោក កឹម សុខា គាត់បញ្ជាក់ ដោយ ទទូចថា «សង្គ្រោះជាតិ» ជា គណបក្ស នយោបាយ ហើយគណបក្ស នយោបាយ វាខុស ពី ចលនា នយោបាយ ព្រោះ គណបក្សនយោបាយ វាមាន គោលការណ៍ និង គោលដៅ របស់ វា ច្បាស់លាស់ ដូច្នេះ តម្រូវ ឲមាន ការរៀបចំក្រុង ជា រចនាសម្ព័ន្ធ ផ្គត់ផ្គង់ ដោយ ឧត្តមគតិ។ រីឯ ចលនា នយោបាយ វិញ គ្មានអ្វីជា គ្រឹះ រស់នៅក្នុង គំនិតនិយម នឹកឃើញអ្វី ធ្វើ ភ្លាម ហើយ ចេះតែដូរ ទៅតាម ការនឹកឃើញ របស់ ខ្លួន។ និយមន័យ ដែល លោក កឹម សុខា លើក មកធ្វើ ជា មេរៀន នយោបាយ នេះ វា គ្មាន ពំនិត នោះឡើយ។ គណបក្សនយោបាយ ឬ ចលនា នយោបាយ វាខុសគ្នានៅ ត្រឹមតែ ពាក្យ តែប៉ុណ្ណោះ ជួន គេ ប្រើ ពាក្យ ចលនា ឬ សម្ព័ន្ធ ព្រោះ នៅក្នុងនោះ គេចង់ បង្ហាញ នូវ ការ ប្រមូលផ្តុំ នៃ ក្រុមគំនិត ជាច្រើន ដែលមាន វេទយិតភាព (sensibilité) ខុសគ្នាខ្លះ តែ មាន គោលការណ៍ និង គោលដៅ នយោបាយ ជា នាមកត្តា (dénominateur) រួម។ ជា ទូទៅ គេប្រើ ពាក្យ គណបក្ស

នយោបាយ ព្រោះ ជា ពាក្យ ងាយស្រួលយល់ សំរាប់ មហាជន ព្រោះ ជា ពាក្យ ដែល គេ ប្រើ នៅក្នុង ឯកសារ ជា ផ្លូវការ ដូច ជា រដ្ឋធម្មនុញ្ញ ច្បាប់ បោះឆ្នោត ។ល។ តែ គ្មាន ច្បាប់ណា ហាមឃាត់ មិនឲ ប្រើពាក្យ «ចលនា» ជំនួស ពាក្យ «គណបក្ស» នោះឡើយ ឧបមា គណបក្ស សង្គ្រោះជាតិ អាច ចុះឈ្មោះ គណបក្សខ្លួន ក្នុងបញ្ជី គណបក្ស នយោបាយ ដោយ ប្រើឈ្មោះ ថា «ចលនា សង្គ្រោះជាតិ»។ ការ ប្រើ ពាក្យ ចលនា ក្តី គណបក្ស ក្តី, សារៈសំខាន់ គឺ វា ឋិត នៅលើ អត្តភាព នៃ ឧត្តមគតិ ជា គោលជំហរ។ បើ ពាក្យ គណបក្ស ឬ ចលនា វា គ្រាន់ តែជា ឈ្មោះ គ្មាន សារជាតិ នយោបាយ ពាក្យ នោះ វា គ្រាន់ តែ ជា សំនៀង ឮសូរ តែ មួយសំណើ តែប៉ុណ្ណោះ។

គណបក្សសង្គ្រោះជាតិ ជា សេចក្តី សង្ឃឹមខ្មែរ ជាថ្មីម្តងទៀត ឬ ជា ឧបករណ៍ របស់ យៀកណាម ដូច គណបក្សប្រជាជន នោះដែរឬ ?

គណបក្សសង្គ្រោះជាតិ ជា គណបក្ស ថ្មី តែ អ្នកដឹកនាំ គណបក្ស ជា អ្នកនយោបាយ ដើងចាស់ ធ្លាប់ មាន គណបក្ស រៀងៗខ្លួន រួចមកហើយ ; ដូច្នេះ គេ អាច សួរ ជាសំណួរ ថា តើ គណបក្សសង្គ្រោះជាតិ ជា ការ បន្ត នៃ គំនិត នយោបាយ, ជា កំណែទំរង់,ជា បុនក្ការ (rénovation) ឬ ជា ការកសាងថ្មី, របស់ អ្នកដឹកនាំ ដើងចាស់ ? សង្កេតភាព (examen) អោយបាន ច្បាស់លាស់ លើ កំណើត និង សកម្មភាព របស់ គណបក្ស អាច អោយយើង រកឃើញ នូវ ចម្លើយនឹង សំណួរ ខាងលើ នេះ។ តែ ចម្លើយ នេះ ទៀត វា គ្រាន់តែជា វិស័យមតិ ផ្ទាល់ខ្លួន របស់យើង នៅក្នុង ទស្សនៈ នៃ វិភាគ ជាបញ្ញា (sous l’angle de l’analyse intellectuelle) តែប៉ុណ្ណោះ ព្រោះ វា គ្មាន គោលបំណង ណាមួយ សំរាប់ សរសើរ ឬ បង្អាប់បង្អោន ដល់ គណបក្ស ឬ អ្នកដឹកនាំ នោះឡើយ។

## កំណើត នៃ គណបក្សសង្គ្រោះជាតិ

គណបក្សសង្គ្រោះជាតិ កើត ពី ការធ្វើ សម្ព័ន្ធ នៃ គណបក្ស សមរង្ស៊ី នឹង សិទ្ធិមនុស្ស នៅក្នុង ឆ្នាំ ២០១២-២០១៣ ដើម្បី បង្រួបបង្រួម អ្នកប្រជាធិបតេយ្យ អ្នកស្នេហាជាតិ និង ជនខ្មែរ ទាំងឡាយ ដែលមាន អារម្មណ៍ ចង់ ផ្លាស់ប្តូរ គណបក្ស កាន់អំណាច។ គណបក្ស ទាំងពីរជា គណបក្ស មាន អាសនៈ នៅក្នុង រដ្ឋសភា អាណត្តិទី៤[5]។ សម្ពន្ធ នេះ គ្មាន អាការ ជា អភិគម នោះទេ ព្រោះ គណបក្ស ទាំងពីរ មិន បានលុប គណបក្ស រៀងៗខ្លួន នោះឡើយ។ ដូច្នេះ គណបក្សសង្គ្រោះជាតិ ជា ការបង្កើតថ្មី។ គោងតែ ធ្វើ ការរំឭក ជា សង្ខេប ដើម្បី ងាយយល់ អំពី ការវិវត្តន៍ នៃ ដើម កំណើត របស់ គណបក្សសង្គ្រោះជាតិះ មុន ការបោះឆ្នោត ថ្នាក់ជាតិ សំរាប់អាណត្តិទី៤ នៃ រដ្ឋសភាព, ធ្លាប់ មាន ការប៉ុនប៉ង រួចម្តងហើយ ធ្វើ អភិគម រវាង គណបក្ស ទាំងពីរ តែ ពេល

[5]គណបក្ស សមរង្ស៊ី មាន អាសនៈ ២៦ ; សិទ្ធិមនុស្ស មាន អាសនៈ ៣។





នោះ គណបក្សសមរង្ស៊ី គ្មាន សេចក្តីស្រើបចិត្ត អ្វីបន្តិចនោះឡើយ នៅក្នុង រូបមន្ត អភិគម នេះ ព្រោះ យល់ឃើញ ថា ខ្លួន មាន វិសិដ្ឋភាព ទាំង ខាងផ្លូវ រូបវន្ត និង បក្កភាព នយោបាយ (maturité politique) ជា ពិសេស គណបក្សសិទ្ធិមនុស្ស មិនទាន់មាន អាសនៈ នៅក្នុង រដ្ឋសភា។ អាស្រ័យហេតុនេះ គណបក្សសមរង្ស៊ី ស្នើរ ដល់ គណបក្សសិទ្ធិមនុស្ស អោយ ចូលរួម ជាមួយ គណបក្សខ្លួន តែម្តង។ សំណើរ នេះហើយ ដែល ជា ឧបសគ្គ សំខាន់ ដល់ ការប៉ុនប៉ង នៃ ការបង្ខិតចូលរួមគ្នា រវាង គណបក្ស ទាំង២។ គេនៅចាំបាន ថា នៅពេលនោះ មាន ជម្លោះ នៃ វិស័យមតិ ជា សំដី វិវាទ រវាង អ្នកដឹកនាំ។ វិវាទនេះ ជា លាភផល បានដល់ គណបក្សកាន់អំណាច ហើយ គេ ឆ្លៀត ប្រើគ្រប់មធ្យោបាយ ក្នុងពេល បោះឆ្នោត ថ្នាក់ជាតិ សំរាប់ អាណត្តិទី៤ យកបាន ចំនួន អាសនៈ ច្រើនដាច់ខាត[6] នៅក្នុង រដ្ឋសភា នាំឲគេ អាចបង្កើត រដ្ឋាភិបាល មិនចាំបាច់ស្វែងរក សម្ព័ន្ធភាព ជា មួយគណបក្ស ដទៃទៀត ដែល មាន អាសនៈ នៅក្នុង រដ្ឋសភា។ ក្សីណនោះ គណបក្សសមរង្ស៊ី បានទទួល ២៦ អាសនៈ រីឯ គណបក្សសិទ្ធិមនុស្សវិញ បានទទួល ៣ អាសនៈ ; តែបើ យកចំនួន សម្លេងឆ្នោត គណបក្សទាំងពីរ មកបូកបញ្ចូលគ្នា ដោយ សន្មត ថា គណបក្សទាំងពីរ រួមគ្នាតែមួយ, នៅក្នុងករណី បែបនេះ គណបក្សនោះ អាចនឹង ទទួលបាន អាសនៈ នៅក្នុង រដ្ឋសភា លើសច្រើនជាង ឆ្ងាយ ពីចំនួន ២៦+៣ ទៅទៀត បើយោងទៅតាម វិធី នៃ ការបែងចែក អាសនៈ ក្នុងច្បាប់បោះឆ្នោត។ គេ សង្កេតឃើញ ថា គណបក្សសមរង្ស៊ី តាំងពី អាណត្តិទី២ មក តែងតែ កើនចំនួន អាសនៈ ជានិច្ចះ អាណត្តិទី២ ទទួលបាន ១៥ អាសនៈ ; អាណត្តិទី៣ ទទួលបាន ២៤ អាសនៈ និង អាណត្តិទី៤ ទទួលបាន ២៦ អាសនៈ។ វឌ្ឍនកម្ម នេះអាច នាំអោយ គេ សួរ ជា សំណួរ ថា បើ គណបក្សសមរង្ស៊ី មិនចូលរួមបង្កើត គណបក្សសង្គ្រោះជាតិ សំរាប់ ការបោះឆ្នោត សំរាប់ អាណត្តិទី៥ តើ គណបក្សសមរង្ស៊ី នឹងអាច បន្ត កើន ចំនួន អាសនៈ បានដែរ ឬទេ ? យើងពិបាក យក ករណីនេះ មកពិនិត្យ ព្រោះ ការបោះឆ្នោត នៅ ស្រុកខ្មែរ ចាប់តាំងតែ ពី អាណត្តិទី២ មក មិនអាចទុក ជា ការបោះឆ្នោត ត្រឹមត្រូវ នោះឡើយ ដែលអាច ឲយើង យកចំនួនអ្នកបោះឆ្នោត ស្របច្បាប់ ក្តី ចំនួន សម្លេងឆ្នោត ដកចេញ ពី ហឹបឆ្នោត ពិត ក្តី មកធ្វើជា ធាតុ វិន្ទន័យ (éléments de réponse) ដើម្បី ឆ្លើយនឹង សំណួរ ខាងលើនេះ។ តែ ចម្លើយ ដែល អាច ឆ្លើយបាន គឺ ឧបមា បើនៅ ស្រុកខ្មែរ មាន ការបោះឆ្នោត មួយ ត្រឹមត្រូវពិត គឺ ច្បាស់ ជា គណបក្សកាន់អំណាច មិនអាច ឈ្នះឆ្នោត បាននោះឡើយ។ ការណ៍ នេះ ជា ការពិតមួយ ដែល ផ្តិតជាប់ នៅក្នុង អារម្មណ៍ ប្រជាជន ខ្មែរ រស់នៅក្នុង សេចក្តីលំបាក គ្រប់ បែបយ៉ាង។

---

[6]គណបក្សប្រជាជន មាន អាសនៈ ៩០, គណបក្សសមរង្ស៊ី ២៦ អាសនៈ គណបក្សសិទ្ធិមនុស្ស ៣ អាសនៈ។

**គណបក្សសមរង្ស៊ី** កើត ចេញ ពី ការបែកមតិ រវាង លោក សម រង្ស៊ី ជា មួយនឹង ទ្រង់ រណាឫទ្ធ នៅក្នុង គណបក្សហ្វុនសាំងប៉ិច។ ដើមឡើយ មាន ឈ្មោះថា គណបក្សជាតិខ្មែរ (១៩៩៤) ក្រោយមក ប្តូរ ឈ្មោះ ជា គណបក្សសមរង្ស៊ី (១៩៩៨)។ គណបក្សនេះ ចូលបោះឆ្នោត ថ្នាក់ជាតិ លើកដំបូង សំរាប់ អាណត្តិទិ២ (១៩៩៨-២០០៣) នៃ រដ្ឋសភា ទទួលបាន ១៥ អាសនៈ ដែល នាំ‌ឲ គណបក្សហ្វុនសាំងប៉ិច ចុះ ចំនួន អាសនៈ ពី ៥៨ មក៤២។ រីឯ គណបក្សប្រជាធិតេយ្យសេរីនិយមពុទ្ធសាសនា ដែល ធ្លាប់មាន ១០ អាសនៈ និង គណក្សមូលីណាកា ដែល ធ្លាប់មាន ១ អាសនៈ នៅក្នុង រដ្ឋសភា ក្នុង អាណត្តិទី១ (១៩៩៣-១៩៩៨) បានបាត់ អាសនៈខ្លួន ទាំងអស់ ; ចំណែកគណបក្សប្រជាជនវិញ មានកើន អាសនៈ ពី ៥១ ទៅ ៦៤ និង កើន សម្លេងឆ្នោត ពី ១ ៤៥៤ ៦៤៩ សម្លេង ទៅ ២ ០៣០ ៨០២ គឺ ថា ទទួល បាន សម្លេងឆ្នោត បន្ថែម ៥៧៦ ១៥៣ សម្លេង (អត្រានៃ ការកើនៈ ៣៩,៦១%)។ តែបើ គេ យក សម្លេងសន្លឹកឆ្នោត គណបក្សហ្វុនសាំងប៉ិច (១ ៥៥៤ ៣៧៤) បូក ជាមួយ គណបក្សសមរង្ស៊ី (៦៩៩ ៦៥៣) គេឃើញថា ចំនួនសម្លេងរួម មានដល់ទៅ ២ ២៥៤ ០២៧, ហើយ ចំនួនរួមនេះ មាន ២២៣ ២២៥ សម្លេង លើស គណបក្សប្រជាជន (អត្រា ចំនួនលើស ១១%) ត្រូវ កត់សំគាល់ថា វិធាន សម្លេង ភាគច្រើននៅ រដ្ឋសភា នៅក្នុង អាណត្តិ ទី២ គឺ សម្លេង ភាគច្រើន គ្រប់គ្រាន់ ២/៣ (majorité des 2/3 requise) ដូច្នេះ គណបក្ស ដែល អាចទុក ថា មាន សម្លេងភាគច្រើន ត្រូវមាន ចំនួន ៨១ អាសនៈ ក្នុងចំណោមចំនួន១២២ អាសនៈ មាន នៅក្នុង រដ្ឋសភា។ ដូច្នេះ គណបក្សប្រជាជន ដែលជា គណបក្ស ឈ្នះឆ្នោត ត្រូវ ការចំនួនសម្លេងបន្ថែម១៧ សម្លេង ដើម្បី អាចនឹង បង្កើត រដ្ឋាភិបាល បាន។ នៅចំពោះមុខស្ថានភាព បែបនេះ គណបក្សប្រជាជន ត្រូវការ ពឹងផ្អែក លើគណបក្សហ្វុងសាំងប៉ិច ដូច គណបក្ស នេះ ជា អ្នកឈ្នះ ឆ្នោត នៅ ក្នុង អាណត្តិទី១ ពឹង លើខ្លួន ដើម្បី បង្កើត រដ្ឋាភិបាល ព្រោះថា ចំនួន អាសនៈ គណបក្ស នេះ បូកនឹង គណបក្ស ផ្សេងទៀត ដែល មាន អាសនៈ នៅក្នុង រដ្ឋសភា ក៏ មិនអាច មាន ៨០ សម្លេង ដែល ជា សម្លេងភាគច្រើន ២/៣ គ្រប់គ្រាន់ ក្នុងចំណោម ចំនួន ១២០ អាសនៈ មាន នៅក្នុង រដ្ឋសភា ដើម្បី អាចនឹង មាន លទ្ធភាព បង្កើត រដ្ឋាភិបាល បាន។ ដូច្នេះ នៅក្នុង អាណត្តិទី២ គណបក្សសមរង្ស៊ី ទោះជា ផ្ទុយនឹងឆន្ទៈខ្លួន (malgré lui) ក៏ បានដើរ តួនាទី ជា គណបក្សប្រឆាំង នៅក្នុងរដ្ឋសភា។ ត្រូវដឹងថា លោក សម រង្ស៊ី ធ្លាប់រងគ្រោះនឹង វិច្ឆេទកម្ម ចង់ សម្លាប់លោក នៅថ្ងៃទី ៣០ មិនា ឆ្នាំ ១៩៩៧ ; នៅពេលនោះ មានមនុស្សស្លាប់ ១៧ នាក់។ នៅចំពោះមុខ ការគំរាម ដល់អាយុជីវិត នេះ លោក សម រង្ស៊ី សម្រេចចិត្ត ចាកចេញ ពី ស្រុកខ្មែរ ទៅ រស់នៅ ឯ ប្រទេស បារាំង អស់ មួយ រយៈ (លោក មាន សញ្ញាតិបារាំង)។ បន្តិចក្រោយមក នៅថ្ងៃ ទី៥ កក្កដា មាន ផ្ទុះ

អាវុធ[7] រវាង កងទ័ព គណបក្សហ្វុនសាំងប៉ិច ជាមួយនឹង គណបក្សប្រជាជន ; ក្សិណ នោះ ទ្រង់ រាណាឫទ្ធ ឋិតនៅ ស្រុកបារាំង (ព្រះអង្គ មាន សញ្ញាតិបារាំង)។ ការផ្ទុះ អាវុធ នេះ នាំឲ ព្រះអង្គ បាត់ដំណែង ជា រដ្ឋមន្ត្រីទី១-ទី១។ នៅថ្ងៃ បុណ្យខួបទី១ នៃ វិច្ឆេទកម្ម ប្រឆាំងលោក, លោក សម រង្សី បានធ្វើ ការអំពាវនាវឲ មាន សន្តិភាព ហើយ វិលត្រឡប់ចូល ស្រុកខ្មែរវិញ ដើម្បី ចូលរួម បោះឆ្នោត ថ្នាក់ជាតិ សំរាប់ អាណត្តិ ទី៣ នៃ រដ្ឋសភាព។ លទ្ធផល នៃ ការបោះឆ្នោត គឺ គណបក្សសមរង្សី ទទួលបាន២៤ អាសនៈ ; រីឯ គណបក្សហ្វុនសាំងប៉ិចវិញ ទទួល បានតែ ២៦ អាសនៈ ប៉ុណ្ណោះ។ នៅ ពេលនោះ គណបក្ស ទាំងពីរ មិនយល់ព្រម ទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោត ; ចោទប្រកាន់ ថា គណបក្សប្រជាជន លួចបន្លំ សន្លឹកឆ្នោត យកឈ្នះ ចំនួន ៧៣ អាស នៈ ហើយ នាំគ្នា សំរេចចិត្តរួម ធ្វើ ពហិការ មិនព្រម ចូលប្រជុំ បើក និតិកាលសភា ជា ផ្លូវការ។ ពេលនោះ សកម្មជន គណបក្ស ទាំងពីរ ប្រមូលផ្តុំគ្នា ធ្វើបាតុកម្ម អហិង្សា ប្រឆាំងនឹង លទ្ធផល នៃការបោះឆ្នោត។ តែ ក្រោយមក គណបក្សហ្វុនសាំងប៉ិច ប្តូរ គោលជំហរ របស់ ខ្លួន សុខចិត្ត ធ្វើ សហការ ជាមួយនឹងគណបក្សប្រជាជន ហើយ សម្រេចចិត្ត ចូលរដ្ឋសភា។ របត់ នេះ បើក ឪកាស អោយគណបក្សប្រជាជន បញ្ជាឲ សកម្មជន របស់ ខ្លួន ធ្វើ បាតុកម្ម ហិង្សា ប្រឆាំងនឹងសកម្មជន គណបក្សសមរង្សី ដែល នៅតែបន្ត ធ្វើ បាតុកម្ម អហិង្សា។ អំពើព្រៃ របស់សកម្មជន គណបក្សប្រជាជន នាំ អោយ សកម្មជន របស់ គណបក្សសមរង្សី ជាច្រើនទទួល រងគ្រោះ ជា ទម្ងន់ មាន អ្នកខ្លះ បាត់បង់ជីវិត។ បន្ទាប់ ពីមាន ការអំពាវនាវ ពី ព្រះមហាក្សត្រ សីហនុ គណ បក្សសមរង្សី ក៏សម្រេចចិត្ត ចូល រដ្ឋសភា តាម ឪវាទ របស់ ព្រះមហាក្សត្រ។ តែមួយឆ្នាំ ក្រោយមក (២០០៤) លោក សម រង្សី ត្រូវបានតុលាការ បើក ការស៊ើបអង្កេត លើ រូប លោក អំពី អំពើ និយាយ បង្ខូចកេរ៍ គណបក្សប្រជាជន និងចោទប្រកាន់ ជាសាធារ ណៈ ដល់ លោក ហ៊ុន សែន ថា ជា អ្នក នៅពីក្រោយ ឃាដកម្ម លោក ជា វិជ្ជា (អ្នក ដឹកនាំ សហជិព) និង ប្រព្រឹត្តិ អំពើ ពុករលួយ។ ដើម្បី គេច ពី បទចោទប្រកាន់ នេះ លោក សម រង្សី បាន ចាកចេញ ពី ស្រុកខ្មែរ មកក្រៅប្រទេស។ នៅ ថ្ងៃទី៣កុម្ភៈ ឆ្នាំ ២០០៥, រដ្ឋសភាព បានដក អភ័យឯកសិទ្ធិ របស់ លោក ជា តំណាងរាស្ត្រហើយ នៅ ថ្ងៃទី ២២ ធ្នូ, តុលាការ កាត់ទោសលោក តាម ទុដ្ឋភាព (contumace) ដាក់ទោស ជាប់ ពន្ធធនាគា ១៨ ខែ និង ពិន័យ ប្រាក់១៤ ០០០ ដុល្លា ស.អ.។ បន្ទាប់មក លោក សម រង្សី ទទួល ការអនុគ្រោះទោស ពី ព្រះមហាក្សត្រ សីហមុនី តាមការស្នើរ របស់លោក ហ៊ុន សែន នៅ ថ្ងៃទី១០ កុម្ភៈ ឆ្នាំ២០០៦។ គេ ដឹងថា មាន ការចរចារ តថ្លៃគ្នា រវាង លោក ហ៊ុន សែន ជាមួយនឹង លោក សម រង្សី ដើម្បី ដូរគ្នា នូវ ការវិលត្រឡប់ ចូលស្រុក

[7] ដើមហេតុ នៃ ការផ្ទុះអាវុធ គឺ លោក ហ៊ុន សែន ទុក ការស្វែងរក ធ្វើ សហប្រតិបត្តិការ រវាង កងទ័ព ខ្មែរក្រហម ជាមួយនឹង ហ្វុនសាំងប៉ិច ជា ការគំរាម ដល់ គណបក្សប្រជាជន។





ខ្មែរ ដោយរួចទោស នឹង ការបោះឆ្នោត យល់ព្រម ពី សំណាក់គណបក្សសមរង្ស៊ី ធ្វើកំណែរដ្ឋធម្មនុញ្ញ ស្តីពី វិធាន នៃ សម្លេងភាគច្រើន គ្រប់គ្រាន់ ពី វិធាន ២/៣ ទៅជា វិធាន ៥០+១ ដែល គេ ដឹង ថា វា ជា អត្ថប្រយោជន៍ សំរាប់ គណបក្សប្រជាជន នៅក្នុង បរិបទ នយោបាយខ្មែរ។ ការណ៍នេះ បាន បង្ហាញ ឲឃើញ គម្លាត រវាង អំពើ នឹង គំនិត របស់ លោក សម រង្ស៊ី ហើយ ជា ទ្រនិច (indicateur) ដែល ចង្អុល ខ្នាត ខ្ពស់ នៃ ចរិយា រេគាមខ្យល់ របស់លោក។ ចាប់ពីពេលនោះមក គ្រប់ ដំណោះស្រាយ នៃ វិវាទ រវាង លោក សម រង្ស៊ី ជា មួយនឹង លោក ហ៊ុន សែន គឺ ផ្អែក ជានិច្ច លើ ចរិយា រេគាមខ្យល់ របស់លោក សម រង្ស៊ី ដើម្បីរកប្រយោជន៍ ផ្ទាល់ខ្លួន និង ក្រុមបក្ស។ អាស្រ័យហេតុនេះ គណបក្ស សមរង្ស៊ី ប្តូររូប បន្តិចម្តងៗ ទៅជាគណបក្ស របស់ ជន មួយក្រុមតូច ដែលមាន របៀបដឹកនាំ ជាគ្រួសារនិយម ផ្អែកលើ ការការពារ ប្រយោជន៍ គ្រួសារជាង ប្រយោជន៍ ទូទៅ។ នៅក្នុង មនោសាស្ត្រ រេគាមខ្យល់ (esprit d'opportunisme) នេះឯង ដែល នាំឲ លោក សម រង្ស៊ី គ្មាន គំនិតនយោបាយ ខ្ជាប់ខ្ជួន សោះឡើយ សូម្បីតែ រក្សា វប្បធម៌ សន្ទនា ដែលគាត់ ទាមទារ ថា ជា ស្នាដៃ ពិសេស របស់ គាត់ ក៏ពុំអាច ធ្វើបានដែរ ព្រោះ គាត់ មានគំនិត ស្មុញទ្រា (idée empêtrée) នៅក្នុងប្រយោជន៍ផ្ទាល់ខ្លួន។ បច្ចុប្បន្ននេះ គាត់ធ្វើ ការអំពាវនាវ អោយមាន ការរួបរួមជាតិ។ ត្រូវដឹងថា នៅក្នុង គំនិត នេះ គឺ គាត់ គ្រាន់តែចង់ ផ្ញើរសារ ចំពោះ លោក ហ៊ុន សែន ថា គាត់ ចង់ រួបរួម ជា មួយនឹង លោក ហ៊ុន សែន តែប៉ុណ្ណោះ ហើយ ដើម្បីបង្ហាញ សន្តិភាព របស់ គាត់ ចំពោះ លោក ហ៊ុន សែន គាត់ តែងតែ ឆ្លៀត គាំទ្រ ដោយប្រយោលដល់ អ្វីៗ ដែល លោក ហ៊ុន សែន ចង់បាន ដូចយ៉ាង ជម្រើស ប្រធាន គ.ជ.ប. ជា អាទិ។ សួរ ថា បើ ដូច្នេះ ដដែលៗ ចុះហេតុអ្វីបានជា លោក សម រង្ស៊ី ចេះ តែ «ឈ្លោះហើយ ជា» រួច «ជា ហើយ ឈ្លោះ» ជាមួយនឹង លោក ហ៊ុន សែន ? បញ្ហានយោបាយ ? វា ច្បាស់ ជាមាន តែ បើ ធ្វើការសង្កេត អោយច្បាស់ យើង ឃើញថា បញ្ហាលាស់ (problème récurrent) ដែល មានកើតឡើង គឺ ចេញពី ចរិតផ្ទាល់ របស់ លោក សម រង្ស៊ី តែម្តង ព្រោះ គាត់ មាន អស្ថិរភាព នៃ សភាវគតិ។ ទង្វើសំដែល (fait répété) នេះ បង្ហាញ អោយឃើញ បន្ថែមទៀតថា លោកសម រង្ស៊ី គាត់ ពុំអាចដូរ ចរិត របស់គាត់បាន នោះឡើយ ព្រោះ គាត់ ជាជន មាន ស្វាមីភក្តិលើខ្លួនឯង (fidèle à lui-même) ណាស់។

**គណបក្សសិទ្ធិមនុស្ស** មានកំណើត ចេញពី មនោសាស្ត្រ យុទ្ធកៈ (esprit militant) នៃ ការប្រយុទ្ធ ការពារ សិទ្ធិមនុស្ស ដែល មាន លោក កឹម សុខា ជា អវគា។ គណបក្សនេះ បង្កើតឡើង នៅ ថ្ងៃទី ១៩ មិថុនា ឆ្នាំ ២០០៧។ គឺ ជា គណបក្ស នវោត្បន្ន (récent) តែ មាន អតិតកាល ចំណាស់ បើ គេ យក លោក កឹម សុខា ដែល ជា ជននយោបាយ (le politicien) ជើងចាស់ ម្នាក់ មកធ្វើ ជា យោង។ នៅក្នុង គណបក្សនេះមាន អតីត



## ការបបួលគ្នាប្រកួត នៃ គណបក្សសង្គ្រោះជាតិ

សេរីការ

នាយករដ្ឋមន្ត្រី ទី ១ នៃ សាធារណរដ្ឋ ប្រជាមានិត កម្ពុជា គឺ លោក ប៉ែន សុវណ្ណ ជា សមាជិក ដែលនាំ ឲមាន ការមិនទុកចិត្ត ពីសំណាក់ ពួក អ្នកប្រជាធិបតេយ្យ ព្រោះ គាត់ ជា អតីត ខ្មែរ យៀកមុីញ ជា ជនកុម្មុយនិស្ត សុទ្ធសាត ទទួលការអប់រំ ពីសំណាក់ បក្សកុម្មុយនិស្តយួន។ ទោះជា លោក ប៉ែន សុវណ្ណ ត្រូវ បាន បក្សកុម្មុយនិស្តយួន ដក ហូត ពីតំណែង ហើយ ចាប់ យក ទៅ ឃុំឃាំង នៅ ស្រុកយួន អស់រយៈ ១០ ឆ្នាំ ពី បទ ប្រឆាំងនឹង ប្រយោជន៍យួន នៅ ស្រុកខ្មែរ ក៏ មិនអាច លុប ឲអស់បាន អតីត កាល ជា អ្នកបំរើ ប្រយោជន៍ បក្សកុម្មុយនិស្តយួន ព្រោះខ្មែរ ភាគច្រើនដាច់ខាត ទុក បក្សកុម្មុយនិស្តយួន ជា អកុសល សំរាប់ ប្រជាជាតិខ្មែរ និង លទ្ធិកុម្មុយនិស្ត ជា សត្រូវនឹង ព្រះពុទ្ធសាសនា។

គណបក្សសិទ្ធិមនុស្ស បង្កើតឡើង ដើម្បី ចូលរួម បោះឆ្នោត។ នៅក្នុង អាណត្តិទី៤ នៃ រដ្ឋសភា។ គណបក្ស នេះ ទទួល បាន ៣ អាសនៈ (ចំនួន សន្លឹក ឆ្នោត ៣៩៧ ៨១៦ ស ម្លេង)។ លទ្ធផល នេះ អាច ចាត់ទុក ជា ជំហានជ័យ ទីមួយ សំរាប់ គណបក្ស ដែល ស្របនឹង ស្មៀត របស់ខ្លួន គឺ «មួយជំហានម្តងៗ»។ ជំហាន ទី១ ជា ការចេញដំណើរ ដ៏ ល្អពិត តែ មិន ជិតដល់ សំរាប់ ធ្វើសញ្ជ័យ ប្រយុទ្ធ ដណ្តើម យក អំណាច (conquérir le pouvoir) បាន នោះឡើយ។ អាស្រ័យហេតុនេះ គណបក្ស ចាំបាច់ ស្វែងរក សម្ព័ន្ធភាព ជា មួយគណបក្ស ណាមួយ ដែលមាន វេទយិតភាព (sensibilité) នយោបាយ ដូចគ្នា ឬ ស្រដៀងគ្នា ដែល នឹងអាច យក មកធ្វើ ជា មូលដ្ឋាន នៃ ឧត្តមគតិក ដើម្បី សាង យុទ្ធសាស្ត្រ នយោបាយ រួម។ ក្បីណនោះ មាន ពាក្យចចាមអារ៉ាម ថា ចិនកុម្មុយនិស្ត គេ នឹងជួយ គ្រប់ មធ្យោបាយ ដល់ ការរួបរួម រវាង គណបក្ស ហ្វុនសាំងប៉ិច, សមរង្សី, សិទ្ធិមនុស្ស និង រណប្ញទ្ធ ដើម្បី បង្កើត គណបក្ស ធំមួយ សំរាប់ ប្រឆាំងនឹង គណបក្ស ប្រជាជន តាម សន្តិវិធី។ ជា ការផម្ទតា ដំណឹង បែបនេះ ជុំរុញ ឲ អ្នកដឹកនាំ គណ បក្សនិមួយៗ យកមកគិតគូរ ដើម្បី ស្វែងរក ប្រយោជន៍។ តែ គេដឹង ថា សម្ព័ន្ធភាព មិន អាច មាន បាន ជា ដាច់ ខាត រវាង គណបក្ស ហ្វុនសាំងប៉ិច, រណប្ញទ្ធ ជាមួយ នឹង គណបក្សសមរង្សី ព្រោះ មេដឹកនាំ គណបក្ស រាជានិយម ទាំងពីរ ឋិត នៅក្រោម ឥទ្ធិពល របស់លោក ហ៊ុន សែន ដូច្នេះ ការប៉ុនប៉ង ណាមួយ ចេញពី ដែន (sphère) ឥទ្ធិពលនេះ, ចំពោះ លោក ហ៊ុន សែន គាត់ ទុក វា ជា អំពើ ក្បត់ ចំពោះគាត់។ ឧទាហរណ៍ មាន ច្រើនណាស់ ដែល យើង មិនចាំបាច់ លើក យកវា មក ពិពណ៌នា នោះ ឡើយ។ ដោយ ហេតុនេះឯង បាន ជា មានតែ គណបក្សសមរង្សី និង សិទ្ធិមនុស្ស ដែល មាន អ្នកដឹកនាំ នៅមាន ស្វ័យភាព មិនដាច់ខាត (autonomie relative) ខ្លះ ចំពោះមុខ លោក ហ៊ុន សែន នាំគ្នា ធ្វើ សម្ព័ន្ធភាព បង្កើត គណបក្សសង្គ្រោះជាតិ ដើម្បី រួម មធ្យោបាយ ទាំង សម្ភារៈ និង ប្រាជ្ញា ចូលរួម បោះឆ្នោត ប្រកួត ប្រជែង ជាមួយនឹង គណបក្សប្រជាជន។ តែ គេ ដឹង ថា ពាក្យ ចចាមអារ៉ាម នេះ វាគ្រាន់តែ

ជា ឧបាយសឹក (stratagème) របស់ ចិន/យួន កុម្មុយនិស្ត ដើម្បី អោយមានការបោះឆ្នោត ក្លែងក្លាយ នៅស្រុកខ្មែរ ព្រោះ វា ជា ការធានា នៃ ស្ថិរភាព ដល់ គណបក្សកាន់អំណាច ដែល ជា អ្នកបំរើប្រយោជន៍ របស់ ពួកខ្លួន។ ចំពោះ គណបក្ស កុម្មុយនិស្តយួន គេទុក ការប្តូរ អ្នកដឹកនាំ នៅស្រុកខ្មែរ ជា ការគំរាម ដល់ ស្ថិរភាពស្រុកយួន និង ការបាត់បង់ ជីវទឹកដី (espace vitale) នៃ ប្រជាជាតិយួន ; រីឯ គណបក្ស កុម្មុយនិស្តចិន វិញ ទុក ការប្តូរ នេះ ជា ការបាត់បង់ ដែនឥទ្ធិពល (zone d’influence) ចិន នៅ ដំបន់អាស៊ី ភាគអគ្នេយ៍។ គួរ កត់សំគាល់ ថា គ្រប់ កិច្ចព្រមព្រៀង សន្តិភាព នៅ ឥណ្ឌូចិន នៅ ឆ្នាំ ១៩៥៤ ក្តី, ឆ្នាំ ១៩៧៣ ក្តី និង ឆ្នាំ ១៩៩១ តែងតែ ហុច ជានិច្ច អត្ថប្រយោជន៍ ដល់ ភាគី កុម្មុយនិស្ត ហើយ ប្រទេសខ្មែរ ជា ប្រទេស រងគ្រោះ ជាង គេបំផុត ទាំង ជីវិតមនុស្ស, ហេដ្ឋារចនាសម្ព័ន្ធ, បូរណភាពទឹកដី និងអធិបតេយ្យជាតិ។ ត្រូវដឹង ថា ប្រទេស តូចៗ បើ អ្នកដឹកនាំជាតិ ធ្វើ អ្វីមួយខុស គឺ មាន កម្មវិបាកភ្លាមៗ ដល់ ប្រជាជាតិ ព្រោះថា ប្រទេស តូចៗ គ្មាន មធ្យោបាយ គ្រប់គ្រាន់ ដើម្បីកែ កំហុស អោយបានរហ័ស ដូច ប្រទេសធំៗ នោះឡើយ ដូចយ៉ាង ស្រុកខ្មែរ រាល់កំហុស របស់ អ្នកដឹកនាំជាតិ បង្កបង្កើត ជានិច្ច ឧបទ្ទវហេតុ (désastre) ដល់ ប្រជាជាតិ។ គួរខ្មែរយើង យល់ឃើញ ថា នៅក្នុង បរិបទ ស្រុកខ្មែរ, ខ្មែរយើង ពុំអាច យក កត្តាពេលវេលាយូរ មក ធ្វើ ផែនការ កលល្បិច (plan-tactique) បាននោះឡើយ ព្រោះដំណើរ «មួយជំហានម្តងៗ» ទោះបី ជា អង្គុក (pas régulier) ក៏ដោយ គឺ ជា ការផ្តល់លទ្ធភាព ទាំងអស់ អោយ យួនកុម្មុយនិស្ត ពង្រឹង អំណាច របស់គេ នៅស្រុកខ្មែរ តាមគណបក្សប្រជាជន ដែល ជា បក្សចំណុះគេ។ រយៈពេល អាណត្តិ នៃ រដ្ឋសភា ប្រាំឆ្នាំ គឺទុក ជា ពេលវេលាយូរ នោះឯង ដូច្នេះ បើ នៅ តែ នាំគ្នា អង្គុយ ចាំតែ បោះឆ្នោត គឺច្បាស់ជា នាំគ្នា អង្គុយចាំ ស្លាប់ ដែល ចាស់បុរាណខ្មែរ ហៅថា ពួក ហានេយ្យំ (qui mérite la mort)។

## មនោសាស្ត្រ នៃ គណបក្សសង្គ្រោះជាតិ

នៅក្នុង ការសាកល្បងពិចារណា របស់យើងនេះ យើង មិន អត្ថាធិប្បាយ អំពី អាការៈក្រៅ របស់ គណបក្សសង្គ្រោះជាតិ នោះទេ ដូចយ៉ាង សកម្មភាព នៃ ការប្រជុំ មហាជនក្តី, ការរៀបចំ នៃរចនាសម្ពន្ធក្តី ។ល។ យើង អត្ថាធិប្បាយ នៅ ក្នុង អត្ថបទនេះ អំពីតែមនោសាស្ត្រនៃគណបក្ស ដើម្បីយល់ដឹង ជាជម្រូវ គោលបំណង ស្វែងរកជ័យជំនះ, ពលិកម្ម, សីលធម៌ នៃ អ្នកដឹកនាំ ដែល សុទ្ធ ជា កត្តា ពភ្លើក (trainant) ព្រលឹងជាតិក្នុង ដំណើរ ថាមវ័ន្ត នៃ បេសកកម្ម ថ្លៃថ្នូរ ដើម្បី សង្គ្រោះជាតិ ដែល គណបក្ស

អះអាង ថា ខ្លួន មាន កម្លាំង រូបវន្ត និង គំនិត គ្រប់គ្រាន់ ដើម្បី ប្រយុទ្ធ តាម សន្តិវិធី គឺ ការបោះឆ្នោត យកជ័យជំនះ លើ គណបក្សកាន់អំណាច បាន។

## គោលបំណង ស្វែងរក ជ័យជំនះ

គោលបំណង សំខាន់ របស់ គណបក្ស នយោបាយ គឺ ជ័យជំនះ ដើម្បី មាន លទ្ធភាព អនុវត្ត នូវ កម្មវិធី នយោបាយ របស់ខ្លួន។ គោលបំណង នេះ មាន នៅក្នុង មនោសាស្ត្រ របស់គណបក្សសង្គ្រោះជាតិ ព្រោះ វា ជា ភារៈអាស្រ័យហេតុ (raison d'être) របស់គណបក្ស។ សួរថា តើ មនោសាស្ត្រ នេះ វា ជា ពន្លឺឆ្លុះ (reflet) នូវ មនោសាស្ត្រ ពិត របស់អ្នកដឹកនាំ ដែរឬទេ ? ដោយបច្ច័យភាព (logiquement) វា គោងតែ មាន ជ័យជំនះ ទើប អាច មាន លទ្ធភាព ប្តូរ អ្នកដឹកនាំជាតិ បច្ចុប្បន្ន តាម សន្តិវិធី បាន។ ដូច្នេះ ជ័យជំនេះ នេះ វា ឋិត នៅក្នុង ក្របខណ្ឌ នៃ ការបោះឆ្នោត ដោយ មាន យុត្តិធម៌ និង សេរី។ អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ តែងតែ បង្ហាញ គោលស្មារតី នេះ ជានិច្ច តាម ឧត្តមប្រយោគ នៅក្នុង រាល់ មីទីង ដើម្បី បន្ទំ សតិអារម្មណ៍ បក្ខជន និង សកម្មជន របស់ខ្លួន សំរាប់ ចូលរួម បោះឆ្នោត តែ ពុំបាន បង្ហាញ តាម ការអះអាង យ៉ាងម៉ឺងម៉ាត់ ថា នៅក្នុង លក្ខខណ្ឌ បែបណា ដែលខ្លួន សុខចិត្ត ចូលរួម បោះឆ្នោត។ ភាពមិនច្បាស់បែបនេះ គេ មើលឃើញ វា ដូច ជា មាន ឧបាយកល សំដែល (ruse répétée) ក្នុង គោលបំណង បោកប្រាស់ ប្រជាជន រស់នៅក្នុង ទុក្ខភ័យគ្មានទីរំពឹង ដូចនៅ ឆ្នាំ ២០១៣។ ត្រូវដឹងថា នៅក្នុង ស្ថានភាព មហន្តរាយ អាចនាំអោយ មនុស្សបាត់អស់ ភារៈ ជា មនុស្សលោក បើ គ្មាន ជំនួយ ផ្នែក ចិត្តតិកិច្ឆា (psychothérapie), សំរាប់ នាំអ្នករងគ្រោះ អោយមករក សភាព ធម្មតា វិញ, ជននោះ ឬ អ្នកទាំងនោះ ឬ ប្រជាជននោះ អាច ជ្រើស ដំណោះស្រាយ ផ្ទុយនឹងវិចារណញ្ញាណ (អវិចារណ៍) ដូចយ៉ាង នៅក្នុងរឿងទុំទាវ, នេន ទុំ យក សុរា ជា ត្រីមុខ ; នៅពេល សង្គ្រាមលោក លើកទី២ ប្រជាជន បារាំង ទទួល ស្គាល់ ដោយ ស្មោះចិត្ត លោក សនាប្រមុខ ប៉េតាំង (Ph. Pétain) ជា ប្រមុខរដ្ឋ ប្រទេសបារាំង ទោះបី លោក ប៉េតាំង ធ្វើ សហការ ជាមួយនឹង របប ហ្វាស៊ីស ក៏ដោយ ; អ្នកនយោបាយ នឹង អ្នករាជការ ខ្មែរ បច្ចុប្បន្ន សុខចិត្ត រស់ នៅក្រោម របប អាណានិគមយួន បែបថ្មី ទោះបី ដឹងច្បាស់ ថា របប នេះ ជា គ្រឿង ពិឃាដ ជនជាតិខ្មែរ តាមវិធីត្រជាក់ គឺ នយោបាយ អាណានិគម នៃ ប្រជាជនយួន នៅ ស្រុកខ្មែរ។

អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ គាត់ ជ្រើសរើស ដោយ ចេតនា យក ដំណោះស្រាយ អវិចារណ៍ (solution irrationnelle) នេះ ព្រោះ វា ជា ដំណោះស្រាយងាយស្រួល សំរាប់ពួកគាត់ ព្រោះ បើ ពួកគាត់ ចាញ់ បោះឆ្នោត ក៏ អាចរស់ ក្នុងឋានៈ ជា ឯកឧត្តម ទទួលបាន អត្ថប្រយោជន៍ជាវត្ថុ គ្រប់បែបយ៉ាង ដូចយ៉ាង ឡាន លុយ ជា អាទិ។ បើ ពួក

គាត់ ឈ្នះឆ្នោត ក៏ នាំគ្នា សុខចិត្ត ទទួលចាញ់ បើ លោក ហ៊ុន សែន គាត់ បញ្ជា អោយចាញ់ ដូចការបោះឆ្នោត ឆ្នាំ ២០១៣ ព្រោះ ពួកគាត់ នឹងបានទទួល អត្ថប្រយោជន៍ ជាវត្ថុផង ហើយ មានបន្ថែម អោយ អត្ថប្រយោជន៍ជាឋានន្តរស័ក្តិ ដូចយ៉ាង មុខងារ ជា អនុប្រធាន និង ប្រធាន គណកម្មការ នៅ ក្នុង រដ្ឋសភា មិន ស្របច្បាប់។ ទង្វើ នេះហើយ ដែល អាច ទុកជា គម្លាត ទី១ រវាង មនោសាស្ត្រ នៃ គណបក្ស នឹង អ្នកដឹកនាំ ព្រោះ **គោលបំណង រក ជ័យជំនះ ទុកជា មោឃ** ដូច្នេះ ការបោះឆ្នោត បែប នេះ គឺ គ្រាន់តែ ជា ការបោះឆ្នោត បង្គ្រប់កិច្ច សំរាប់ តែ បំរើ អត្ថប្រយោជន៍ ដល់ គណបក្សកាន់អំណាច ឬ ជា សមាយោគ (combinaison) ដើម្បី ចែក ចំណេញគ្នា លើ ខ្នង បណ្តារាស្ត្រ និង សកម្មជន នៃ គណបក្ស តែប៉ុណ្ណោះ។

**សម្បជានមុសាវាទ** ឬ កុហក ដោយចេតនា (mensonge intentionnel) របស់ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ជា គម្លាត ទី២ នៅ ចំពោះមុខ មនោសាស្ត្រ នៃ គណបក្ស។ ការភូតកុហក ក្នុងនយោបាយ ជា កំហុសសីលធម៌មួយ ព្រោះ វា នាំមក នូវ កម្មវិបាក អាក្រក់ បំផុត ដល់ សង្គម ហើយ បើ ការភូតកុហក នេះ វា ក្លាយ ជា វប្បធម៌ សំរាប់តែ រក អត្ថប្រយោជន៍ផ្ទាល់ខ្លួន វាជា ឧក្រិដ្ឋកម្ម សំរាប់ ប្រជាជាតិ ព្រោះ វា ជា មូលហេតុ នៃ ការបាត់បង់ ប្រយោជន៍ជាតិ។ គណបក្ស ហ្វុនស៊ាំងប៉ិច បានបាត់បង់ ការគាំទ្រ ពីសំណាក់ ប្រជាពលរដ្ឋ ដោយសារ មូលហេតុ នេះឯង។ តើ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ កំពុង ដើរ តាម គន្លង របស់ ទ្រង់ រណឬទ្ធ ? ចម្លើយ ថា ពិត ឬ មិនពិត វា ឋិត នៅលើ ទង្វើ ដែល ពួកគាត់ កំពុងធ្វើ ព្រោះ អំពើ វា ពុំអាច លាក់បាំង ការពិត រហូត បាន នោះឡើយ ដ្បិទ អំពើ ល្អ វា តែងតែ នាំមក នូវ ផលល្អ ; រីឯ អំពើអាក្រក់ វិញ វា តែងតែ នាំមកនូវ ផលអាក្រក់ ព្រោះ ថា ហេតុទៅនិងផល (cause et effet) នេះ វា គ្រប់គ្រង ដោយ ច្បាប់ ធម្មជាតិ។ គេ អាច កុហកមនុស្សម្នាក់ ឬ មួយក្រុម បានមួយថ្ងៃ ឬ មួយ ខែ, តែ គេ ពុំអាច កុហក ប្រជាពលរដ្ឋ បានរាល់ផង នោះឡើយ។ នៅ ស្រុកខ្មែរ ការភូតកុហកគ្នា ដើម្បី រស់ វា ក្លាយ ទៅជា វប្បធម៌ជាតិ ជាពិសេស នៅក្នុង មជ្ឈដ្ឋាន អ្នកនយោបាយ គ្រប់ ទំនោរគំនិត, ហេតុនេះឯងបានជា ពួកគាត់ បាត់ ការទុកចិត្ត ពីសំណាក់ ប្រជាជន ហើយ ភាគច្រើន ទុក អ្នកនយោបាយ ជា អ្នកបោកប្រាស់ អាជីព តែម្តង។ អាស្រ័យហេតុនេះ បាន ជា នៅ ក្នុង ជីវិតភាពនយោបាយខ្មែរ (la vie politique) គេឃើញថា អ្នកនយោបាយ និង ប្រជាជន រស់នៅក្នុង លោកពីរ ផ្សេងគ្នា។

## ពលកម្ម និង សីលធម៌

គម្លាត ដែល បាន រៀបរាប់ ខាងលើ នេះ វា ចោទ ជា បញ្ហា នៃ ពលកម្ម និង សីលធម៌ របស់ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ។ ម្នាក់ៗ ហាក់បីដូច ជា ជំពាក់ គុណ លោក ហ៊ុន សែន៖ ឧទាហរណ៍ ជាក់ស្តែង គឺ ករណី លោក គឹម សុខា គឺថា នៅពេលថ្មីៗ នេះ ត្រូវបាន អ្នកតំណាងរាស្ត្រ គណបក្សកាន់អំណាច គេ បោះឆ្នោត ហូតងារ របស់គាត់ពី តំណែង អនុប្រធានទី១ រដ្ឋសភា តែ ក្រោយបន្តិចមក គណបក្សកាន់អំណាច គេ អោយ គាត់ ធ្វើជា ប្រធាន នៃ ការប្រជុំ សភា ប្រទេស និយាយ ភាសាបារាំង ដើម្បី លំអ របប ដឹកនាំ លើ ឆាក អន្តរជាតិ ថា ស្រុកខ្មែរ ជា ប្រទេស អនុវត្តន៍ លទ្ធិប្រជាធិបតេយ្យ ព្រោះសមាជិក នៃ គណបក្សប្រឆាំង ត្រូវ បាន គណបក្សកាន់អំណាច ជ្រើសរើស អោយធ្វើជា ប្រធាន អង្គប្រជុំ ថ្នាក់អន្តរជាតិ។ ទង្វើ នេះ ជា កលយុទ្ធនយោបាយ តែ លោក គឹម សុខា គាត់ យល់ ឃើញ គ្មានលជ្ជី (គ្មានអៀនខ្មាស់) ថា ជា កិត្តិយស សំរាប់ គាត់ ទៅវិញ។ ដូចគ្នា នឹងលោក យ៉ែម ប៉ុញ្ញារិទ្ធ, ជា ឧឡារជន (éminence grise) នៃ គណបក្សសង្គ្រោះជាតិ, ដង្ហែរ លោក ឈាន វុន, ទៅ សួរ សុខទុក្ខ អ្នកតំណាងរាស្ត្រ រង គ្រោះ ពី អំពើ ព្រៃផ្សៃ ដែល គេ មាន ការសង្ស័យ ថា គណបក្ស របស់ លោក ឈាន វុន (គណបក្សប្រជាជន) ជា អ្នក នៅពីក្រោយ អំពើអាក្រក់នេះ។ ទង្វើ បែប នេះ វា បង្ហាញ អោយ ឃើញ ថា ជីវិតភាពនយោបាយខ្មែរ វា ដូច ជា បាយឡុកបាយឡ។ តើ លោក គឹម សុខា ក្តី លោក យែម ប៉ុញ្ញឫទ្ធិ ក្តី សុខចិត្ត បោះបង់ កិត្តិយសខ្លួន ចោល ព្រោះ ចង់ បាន អត្ថប្រយោជន៍ផ្ទាល់ខ្លួន ជា សម្ភារៈ និងខ្លាច បាត់ បុព្វសិទ្ធិ ជា ឯកឧត្តម របស់ ពួកគាត់ នោះឬ ? បើជាការពិត, សួរថា តើត្រង់ណាទៅ ដែល ហៅ ថា ពលកម្ម និង សីលធម៌ ? ត្រូវដឹងថា ធ្វើពលកម្ម រក ប្រយោជន៍ វាមានឈ្មោះ របស់វា ហៅថា **បេតាមខ្យល់**។ ការណ៍ នេះ ធ្វើ ឲ យើង នឹកឃើញ ដល់ ករណី លោក សម រង្ស៊ី និង ទ្រង់ រណឫទ្ធ ទទួលអំណោយ ជាកម្រៃ ពី លោក ហ៊ុន សែន ដែល ជា អំណោយ ចង្រៃ ដល់ អាត្មា ព្រោះ ពួកគាត់ គ្មាន គោលការណ៍ កិត្តិយស ឬ សេចក្តីថ្លៃថ្នូរ ដែល ជា មូលដ្ឋាន នៃ សីលធម៌ នយោបាយ។ ត្រូវ ដឹងថា បើទុកខ្លួន ជា ជន មាន កិត្តិយស ជា បឋម គោងតែ ខ្លួនឯង មាន សារជាតិ នេះសិន ហើយ ធ្វើ សកម្មភាព ស្វែង រក ប្រយោជន៍ជាតិជាគោល ពុំនោះកិត្តិយស ជា ឯកឧត្តម ឬ សម្តេច នេះនោះ ឬ ជា សេដ្ឋី (ឧកញ្ញា) វា ដូចជា ផ្លែល្វា តែប៉ុណ្ណោះ។

## កម្លាំង រូបវន្ត និង គំនិត



# ការបបួលគ្នាប្រកួត នៃ គណបក្សសង្គ្រោះជាតិ

សេរីការ

តើ លោក គឹមសុខា និង បក្សពួកគាត់ កំពុង បើក យុគថ្មី តែនាំគ្នាដើរ តាម គន្លង ចាស់ ឬ ? លោក សម រង្ស៊ី គាត់និយាយ មិនខុសទេ ថា លោក កឹម សុខា និង គាត់ ជា មនុស្ស តែមួយ។ យើង យល់ឃើញ ដូច្នេះដែរ ព្រោះ គំនិត នយោបាយ របស់លោក ទាំង ពីរ ដូច ជា ដៃទន្លេ ពីរ ហូរចូល ទៅក្នុង សមុទ្រ នៃ យុទ្ធសាស្ត្រ យួនកុម្មុយនិស្ត តែមួយ គឺ ដំណើរ នៃ ខ្សែ ទឹក នាំ ស្រុកខ្មែរ ហូរ ចូល សំណាញ់ កុម្មុយនិស្ត ដែល ពួកគាត់ អោយ ឈ្មោះថា ដំណើរ ទៅរក ការបោះឆ្នោត ហាក់បីដូចជា នៅស្រុកខ្មែរ មិនដែលមានការ បោះឆ្នោត ម្តងណាឡើយ ហើយ ការបោះឆ្នោត ជា ដំណោះស្រាយ ទាំងអស់ សំរាប់ ដោះ ស្រាយ គ្រប់បញ្ហា នៅស្រុកខ្មែរ។

តាម ខ្សែទឹក នេះ ពួក គាត់កំពុង រកមធ្យោបាយ ដោះស្រាយ បញ្ហាខាងក្រោម ខ្សែទឹក (en aval) គឺ គិត តែនាំគ្នា រៀបចំបោះឆ្នោត ផ្ទុយនឹង ការចាំបាច់ នៃ ស្ថានភាព ដែល តម្រូវ អោយ ដោះស្រាយ បញ្ហា ខាងលើខ្សែទឹក (en amont) គឺ ការធានា គ្រប់ បែប យ៉ាង អោយ មាន ការបោះឆ្នោត ដោយ សេរី និងយុត្តិធម៌។ ការបោះឆ្នោត ជា សិទ្ធកម្ម (acte accompli légalement) មាន ចែង នៅក្នុង រដ្ឋធម្មនុញ្ញ, ដូច្នេះ លើកយកវា មក ធ្វើជា ទិដៅ នៃ ដំណើរ វាគ្មាន ន័យអ្វីសោះ នោះឡើយ ព្រោះ វា ត្រូវ តែមាន កើត ឡើង ជា ចាំបាច់។ ការបោះឆ្នោត ជា សារជាតិ របស់គណបក្សកាន់អំណាច ដើម្បី គេ អាច រក្សា អំណាច របស់គេ។ ផ្ទុយទៅវិញ ការបោះឆ្នោត ស្របច្បាប់ វា ជា សត្រូវ របស់ បក្ស ព្រោះ វា ជា ផ្លូវ មរណៈ នៃ របប របស់គេ។ ដូច្នេះ **ការបោះឆ្នោត ប្រកប ដោយ សេរី និង យុត្តិធម៌** នេះឯង ដែល ជា ទិដៅ នៃ ដំណើរ ទៅរក ការបោះឆ្នោត ព្រោះវា ជា អត្ថរស់ នៃ លទ្ធិប្រជាធិបតេយ្យ។ ធ្វើអ្វីផ្ទុយ ពី អត្ថរស់ នេះ ជា អំពើរ ដែល អោយ មាន គ្រោះថ្នាក់ ដល់ ប្រជាជាតិខ្មែរ។ ឧទាហរណ៍ មានស្រាប់ នៅក្នុង ការបោះ ឆ្នោត ទាំងឡាយ ដែល ធ្លាប់ មានរួចមកហើយ, តែបើ អ្នកដឹកនាំ គណបក្សសង្គ្រោះ ជាតិ មិន យក វា មក ធ្វើ ជា មេរៀន, រឿងហ្នឹង វា ជាបញ្ហា សតិសម្បជញ្ញៈ និង ស្មារតី (mémoire) របស់ពួកគាត់។

ទោះយ៉ាងណា គណបក្សសង្គ្រោះជាតិ នៅមាន សក្តានុពល អាចបំពេញ បេសកកម្ម ខ្លួន ជា ប្រតិបក្ស ទោះជា អ្នកដឹកនាំខ្លួន មាន ទុព្វលភាព (défaillance) ក្នុង ជម្រើស នៃ យុទ្ធសាស្ត្រ ស្របតាម បញ្ហា។ គណបក្សសង្គ្រោះជាតិ មាន កម្លាំង រូបវន្ត គឺ សមាជិក, សកម្មជន និង អ្នកគាំទ្រ ជាច្រើន ដែល អាច បញ្ចេញ សម្រែក យុត្តិធម៌ លាន់ឮរំពង។ ប្រជាករ (masse) នេះ ជា កម្លាំងឈានមុខ អហិង្សា ដើម្បី ប្តូរ អ្នក ដឹកនាំ ប្រជាហិង្សក៍ (dirigeants tyranniques)។ បំណង នេះ ជា មហិច្ឆិតា ស្រប ច្បាប់ និង ជា សិទ្ធកម្ម ក្នុង ករណីយកិច្ច ជា ពលរដ្ឋ (citoyen)។ កតិកា នេះឯង បង្ក បង្កើត ជា កម្លាំង គំនិត ដែល មិន អាច មាន កម្លាំង ណាមួយ អាច កំទិច វា បាន ព្រោះ វា បិត នៅក្នុង សតិសម្បជញ្ញៈ របស់ពលរដ្ឋ ម្នាក់ៗ។ តែ អ្នកដឹកនាំ គណបក្ស

ង្គ្រោះជាតិ, ពួកគាត់ ឆ្លៀត យក កម្លាំង នេះ ធ្វើជា សិទ្ធិប្រទាន (procuration) សំរាប់ ធ្វើការសន្ទនា ជាមួយនឹង គណបក្សកាន់អំណាច ដើម្បី រក ប្រយោជន៍ផ្ទាល់ខ្លួន ដែលនាំអោយ កម្លាំង នៃ ប្រជាករ ប្រកុន នៅចំពោះ មុខអំណាចផ្តាច់ការ។ ដើម្បីបង្ហាញនូវ ភាព វិជ្ជមាន នៃ វប្បធម៌ សន្ទនា, នៅ ពេលថ្មី នេះ លោក យែម ប៉ុញឫទ្ធ អ្នកនាំពាក្យ របស់ គណបក្សសង្គ្រោះជាតិ ថ្លែង ជា សាធារណៈ ថា គណបក្ស របស់គាត់ មាន សោមនស្ស ក្នុង ជំនួប (ក្នុងខែ កុម្ភៈ ២០១៦) ជាមួយនឹង គណបក្សកាន់អំណាច ព្រោះ វា នាំមកនូវ ដំណោះស្រាយ៖ «បញ្ហា តែងតែមាន ដំណោះស្រាយ ហើយដំណោះស្រាយ ដ៏ល្អគឺ វប្បធម៌សន្ទនា»។ ត្រូវ ដឹកថា ដំណោះស្រាយ ដ៏ល្អ របស់ លោក ប៉ុញ្ញឫទ្ធិ នោះ គឺ គណបក្សកាន់អំណាច គេ សម្រេច អោយ ឡាន មួយ គ្រឿង សំរាប់ ប្រើ និង សហការី ៩នាក់ ដល់ ប្រធាន តំណាងរាស្ត្រ គណបក្ស សម្លេងភាគតិច នៅក្នុង រដ្ឋសភា ដូចគ្នានឹង ប្រធាន តំណាងរាស្ត្រ គណបក្ស សម្លេងភាគច្រើន ដែរ។ នេះ ហើយ ជននយោបាយ ថ្មី (le nouveau politicien) របស់ គណបក្សសង្គ្រោះជាតិ ! ដែល គេ នឹកស្មាន ថា ជា «កម្លាំង នៃ សេចក្តីសង្ឃឹម ថ្មី របស់ ប្រជាជាតិខ្មែរ»។ បើ លោក យ៉ែម ប៉ុញ្ញឫទ្ធិ គាត់ បន្ត ថ្លែង ជាប្រព័ន្ធិក (systématique) នូវ សំដី បែប នេះ ច្បាស់ ជា គាត់ នឹងក្លាយ ជា មហាសេដ្ឋី ថ្មី មួយទៀត នៅ ក្នុង បញ្ជីរាយឈ្មោះ នៃ អ្នកដឹកនាំបក្ស (nomenklatura) ដែលមាន សគុណ ដល់ គណបក្សកាន់អំណាច។ តែ លោក ប៉ុញ្ញឫទ្ធិ ភ្លេច គិត ថា គាត់ អាច ក្បត់ ប្រជាជនបាន ព្រោះ ប្រជាជន គ្មាន អំណាច អាច ផ្តន្ទាទោស គាត់បាន នា បច្ចុប្បន្នកាលនេះ តែ បើ គាត់ ក្បត់ លោក ហ៊ុន សែន និង អំណាចយួនកុម្មុយនិស្ត នៅស្រុកខ្មែរ វិញ ក្នុង ឋានៈ ជា និរសា (agent de liaison) ស៊ីកម្រៃ គឺ ច្បាស់ ជា នឹងមាន បញ្ហា ដល់ សុវត្ថិភាព របស់គាត់ ជា ពុំខាន។ ល្បែងបែបនេះ ពួកអ្នកដឹកនាំ គណបក្សសមរង្ស៊ី ធ្លាប់ លេងរួចហើយ ហើយ នរណា ក៏ដឹងដែរ ថា លទ្ធផល ជាអវិជ្ជមាន ក៏មានច្រើន ល្មម យកវា មកធ្វើ ជា មេរៀន បានដែរ។ តែ អ្នកដឹងនាំ គណបក្សសិទ្ធិមនុស្ស ឆ្លៀត យក ហេដ្ឋារចនាសម្ព័ន្ធ របស់ គណបក្សសង្គ្រោះជាតិ ក្នុងឋានៈ ជា សមាជិក ពេញច្បាប់ មក ធ្វើ ជា មធ្យោបាយ រក ប្រយោជន៍ ផ្ទាល់ខ្លួន ម្តងម្នាក់ ក្នុង កាលៈទេសៈ ដែល លោក សម រង្ស៊ី ត្រូវ លោក ហ៊ុន សែន កំពុងវាយប្រហារ។ នេះហើយ ដែលគេហៅថា នយោបាយបំបែក ដើម្បី ងាយស្រួលត្រួតត្រា។

---

## សេចក្តីសន្និដ្ឋាន

---

តើ ការបបួលគ្នាប្រកួត នៃ គណបក្សសង្គ្រោះជាតិ ជា មួយ គណបក្សកាន់អំណាច នាឆ្នាំ ២០១៧-២០១៨ អាចចាត់ទុក ជា គុណប្រយោជន៍ (enjeu) សំរាប់ ប្រជាជាតិខ្មែរ ដែរឬទេ ? បើតាម យោបល់ របស់យើង ការបបួលប្រគួតគ្នា នេះ វា មាន អាការ ជា



## ការបបួលគ្នាប្រកួត នៃ គណបក្សសង្គ្រោះជាត

សេរីការ

ការបបួលប្រគួត ចម្បាប់អង់គ្លេស (catch) ដែល មាន  ការរៀបចំ ទុក  ជាមុន រវាង អ្នកប្រគួត គឺថា មាន អ្នកឈ្នះ មាន អ្នកចាញ់ រួចស្រេចហើយ តែ គេ មិនអោយ អ្នកទស្សនា ដឹងមុន  ជាដាច់ខាត។  ក្នុង ការ បបួលប្រគួត នេះ អ្នក ដែល បន្ត រស់ នៅ ក្រោម របប អាណានិគមយួន បែបថ្មី គឺ ប្រជាជនខ្មែរ នោះឯង។